# ប្រាសាទអំបែងធំ

ប្រាសាទអំបែងធំ មានទីតាំងស្ថិតនៅភូមិព្រិច ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ ៨០គីឡូម៉ែត្រខាងជើងទីរួមខេត្តកំពង់ធំ និងស្ថិតនៅភាគឦសានទីប្រជុំជនឃុំសាគ្រាមប្រមាណ ៤គីឡូម៉ែត្រ។ ទីតាំងនេះ ស្ថិតនៅមិនឆ្ងាយពីតំបន់ប្រាសាទបាកាណក្នុងទឹកដីស្រុកសង្គមថ្មី ខេត្តព្រះវិហារប៉ុន្មានឡើយ ពោល គឺមានន័យថា បើតំបន់បាកាណ ជាក្រុងដ៏សំខាន់មួយនៅសម័យអង្គរ ទីតាំងប្រាសាទអំបែងធំក៏អាចជាសហគមន៍មនុស្សធំមួយគ្រាន់បើដែរ។ ដ្បិត នៅម្តុំប្រាសាទអំបែងធំ មានប្រាសាទបុរាណយ៉ាងតិចក៏ជាង ១០កន្លែង ដែលប្រាសាទទាំងនោះមានអាយុកាលនៅរវាងស.វ.ទី១០-១១។

ប្រាសាទអំបែងធំ ហាក់ស្ថិតនៅឆ្ងាយពីក្រសែភ្នែកអ្នកស្រាវជ្រាវមកពីតំបន់អឺរ៉ុប ដ្បិតនៅមុនស.វ.ទី២១ ពុំធ្លាប់មានអ្នកស្រាវជ្រាវណាបានសិក្សាអំពីប្រាសាទនេះឡើយ ដែលអាចមកពីទីតាំងនេះនៅឆ្ងាយពីទីប្រជុំជនពេក ហើយជាតំបន់ព្រៃក្រាស់ និងត្រូវធ្វើដំណើរដោយជិះទូកឆ្លងស្ទឹងមួយ ព្រោះទីតាំងនេះពុំមានស្ពាន។ ប៉ុន្តែ មកដល់ឆ្នាំ២០០៨ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសហការជាមួយសាលាបារាំងចុងបូព៌ាប្រទេស បានចុះបញ្ជីប្រាសាទនេះ នៅក្នុងសៀវភៅបញ្ជីសារពើភណ្ឌស្ថានីយបុរាណវិទ្យានៅខេត្តកំពង់ធំ។[១]

បើស្តាប់ឮឈ្មោះប្រាសាទថា "អំបែងធំ" ហាក់ដូចជាចម្លែកបន្តិច ដ្បិតនៅទូទាំងប្រទេសកម្ពុជាមិនធ្លាប់មានប្រាសាទណាមួយមានឈ្មោះបែបនេះឡើយ។ អ្នកភូមិមួយចំនួនដែលរស់នៅក្បែរៗប្រាសាទរៀបរាប់ថា "*កាលពីមុនមក គេហៅប្រាសាទនេះថា ប្រាសាទអំបែង ហើយក្រោយមកក៏គេហៅថា អំបែងធំ ដ្បិតគាត់យល់ថា ប្រាសាទនេះជាប់ទាក់ទងនឹងជំនឿនៃការបន់ស្រន់សុំអំបែងចាន ឬអំបែងឆ្នាំង....*"។ តាមការរៀបរាប់នេះ យើងពិបាកនឹងជឿថាប្រភពនៃឈ្មោះប្រាសាទនេះកើតឡើងពីរឿងនេះណាស់ ដ្បិតយើងគប្បីដឹងថា ការបង្កើតជាស្ថាននាមអ្វីមួយនៅក្នុងផ្នត់គំនិតមនុស្សខ្មែរ គេច្រើនតែផ្តោតទៅលើបរិស្ថានទូទៅនៅទីនោះស្រាប់ដូចជា រុក្ខនាម សត្វនាម.....។ យើងគិតថា ឈ្មោះ "អំបែងធំ" នេះអាចចេញពីប្រភពអ្វីមួយផ្សេងដែលយើងមិនដឹង។ ឧទាហរណ៍ថា កាលពីមុនមកគេឃើញថ្មបញ្ចុះនៅទីនោះ ដែលមានចោះរន្ធជុំវិញក្នុងនិម្មិតរូបនៃទេពក្នុងព្រហ្មញ្ញសាសនា តែអ្នកស្រុកមិនស្គាល់ក៏អាចហៅថ្មនោះថា "អំបែង" បានដែរ។[២] ជួនកាលទៀត គេឃើញស្នាមអ្វីមួយរាងដូចរន្ធមូលៗនៅជាប់នឹងប្រាសាទ ដូចស្នាមនៅប្រាសាទ

---

[១] សូមមើលសៀវភៅបញ្ជីស្ថានីយបុរាណខេត្តកំពង់ធំ ឆ្នាំ២០០៨ ទំព័រ ៥៣

[២] Boisselier 1966: 206-207.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ស្រីគ្រប់ល័ក្ខណក្នុងតំបន់ប្រាសាទសំបូរព្រៃគុក ក៏គេអាចហៅថា "អំបែង" ក៏មាន ឬអាចឃើញអ្វីផ្សេងពីនោះដែលមានសណ្ឋានជារន្ធមូលៗដូចអំបែង។ បើគិតទៅវាប្រៀបដូចជានៅប្រាសាទភ្នំស្រះខ្ទៅដែរ ពោល គេហៅថាស្រះខ្ទៅមិនមែនសំដៅលើប្រាសាទទេ គឺគេសំដៅលើថ្មនៅជុំវិញស្រះដែលមានចម្ងាយប្រមាណ៤០០ម៉ែត្រពីប្រាសាទដែលមានរាងរិលវង់ដូចគូទខ្ទៅ ក៏គេហៅស្រះនោះថា "ស្រះខ្ទៅ" តែគេបានច្នៃរឿងព្រេងទៅជា មានព្រះមហាក្សត្រចិញ្ចឹមសត្វខ្ទៅនៅក្នុងស្រះទៅវិញ។ អ្វីដែលគួរចាប់អារម្មណ៍មួយទៀត គឺនៅឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ មានទួលបុរាណមួយឈ្មោះថា "ស្បូវអំបែង"។ ករណីនេះ ពាក្យ "អំបែង" អាចជាប្រភេទមួយនៃស្បូវក៏ថាបាន ពោល គឺអាចជាឈ្មោះរុក្ខនាមដែរ។

បើក្រឡេកមើលវចនានុក្រមខ្មែរវិញ "អំបែង" មានថ្នាក់ពាក្យជានាមសព្ទដែលមានន័យថា បន្ទះបំណែកនៃក្អម ផ្ទាំង ចានជាដើម (អំបែងក្អម អំបែងចាន) និងន័យមួយទៀតថា គឺក្អមដីឬផ្ទាំងដីដែលគោះចោះត្រង់ក្អេងម្ខាងឲ្យមានចន្លោះធំល្មមដល់ការសម្រាប់លីងអ្វីៗ (ឧទា. លីងពោតពីរបីអំបែង)។[៣] នៅក្នុងសិលាចារឹកបុរាណខ្មែរ ក៏មានកត់ត្រាពាក្យ "អំបែង" ដែរ តែគេសំណេរដែលកត់ត្រាជា "អំបេង" ដ្បិតនៅសម័យបុរាណមិនមានប្រើស្រៈ "ែ" ដូចសព្វថ្ងៃនេះឡើយ។ ប៉ុន្តែ ន័យរបស់ពាក្យនេះនៅក្នុងសិលាចារឹកភាគច្រើនជាឈ្មោះរបស់មនុស្ស។ ឧទាហរណ៍ សិលាចារឹកប្រាសាទកំផុស ខេត្តព្រះវិហារ ចុះបញ្ជីលេខ K.669[៤] មានរៀបរាប់អំពីនារីម្នាក់ឈ្មោះថា "អំបេង", សិលាចារឹកភ្នំបាសិត ខេត្តកណ្ដាល K.78[៥] រៀបរាប់ពីបុរសម្នាក់ឈ្មោះ "អំបេង" ដូចគ្នា។[៦]

ប្រាសាទអំបែងនំ កសាងឡើងអំពីឥដ្ឋ មានតួប៉មបីរត់ជួរគ្នាពីជើងទៅត្បូង បែរមុខទៅទិសខាងកើត សាងនៅលើខឿនថ្មបាយក្រៀមខ្ពស់ផុតពីដី មានកសិន្ធុទឹកព័ទ្ធជុំវិញ ផ្លូវចូលពីទិសខាងកើត និងមានស្រះចំនួនពីរនៅខាងជើង ។ តួប៉មកណ្ដាលនៅមានរូបរាងល្អច្រើន តែតួប៉មពីរទៀតនៅអមសងខាងបានបាក់បែកផ្នែកដំបូល នៅសល់ត្រឹមតែកំណាត់ដំបូលចុះមកក្រោម។ តួប៉មទាំងបីនេះ មានទ្វារចូលពីទិសខាងកើត ហើយទិសបីផ្សេងទៀតគេមានលម្អជាទ្វារបញ្ឆោត (រូបលេខ១-៧)។ ការលម្អនៅលើតួប៉មប្រាសាទទាំងបីនេះ មានលក្ខណៈដូចគ្នានឹងគុកលិចឬប្រាសាទត្នោតជុំខាងលិចនៅក្នុងស្រុកបារាយណ៍ស្ទើរទាំងស្រុង ពោល គឺគេតម្រៀបឥដ្ឋជាថ្នាក់ៗស្តួចទៅ

---

[៣] ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧: ១៧៧៨។

[៤] Coedès 1937: 29.

[៥] Coedès 1954: 12.

[៦] Saveros Pou 1992: 20.

លើ ហើយក្នុងថ្នាក់នីមួយៗបង្ហាញជាក្បាច់ទ្វារបញ្ឆោតគ្រប់ជាន់(រូបលេខ៨)។[៧]

ដោយឡែក ក្បាច់លម្អស្ថាបត្យកម្មដែលធ្វើអំពីថ្មភក់នៅប្រាសាទនេះ ពុំសូវមាននៅសល់ច្រើនដូចប្រាសាទផ្សេងៗទេ ពោល ក្រៅអំពីស៊ុមទ្វារប្រាសាទ យើងឃើញមានតែជើងទម្របដិមាមួយ និងបំណែកសសរពេជ្រវាងប្រាំបីជ្រុងមួយប៉ុណ្ណោះ (រូបលេខ៩-១០)។ សសរពេជ្រនេះ បាក់បែកនៅសល់កំណាត់ខ្លីប្រវែង ២០ស.ម.ប៉ុណ្ណោះ ដែលលម្អដោយក្បាច់ត្របកឈូក និងក្បាច់អង្គុរ ក្នុងទម្រង់សិល្បៈរចនាបថប្រែរូប ឬបន្ទាយស្រីនាស.វ.ទី១០(រូបលេខ១១)។[៨]

នៅប្រាសាទអំបែងធំ គេធ្លាប់រកឃើញគោលចារឹកមួយផ្ទាំងដែលបាក់បែកជាពីរកំណាត់។ គេបានយកគោលចារឹកនេះទៅរក្សាទុកនៅវត្តក្រយា ហើយក្រោយមកនៅឆ្នាំ២០១៥ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ បានយកសិលាចារឹកនេះមកតភ្ជាប់គ្នាវិញនិងរក្សាទុកនៅសារមន្ទីរខេត្តកំពង់ធំ។ អក្សរចារឹកនេះ គេចារឹកនៅលើគោលសីមាដែលមើលទៅដូចផ្កាឈូក ជាពីរផ្នែក ហើយចារឹកជាភាសាខ្មែរបុរាណ។ ផ្ទាំងទី១ មានចារឹកចំនួន ២៨ បន្ទាត់ តែដើមៗវគ្គនៃបន្ទាត់នីមួយៗមានរលុបអក្សរច្រើន និងផ្ទាំងទី២ មានចារឹកចំនួន ៤៤ បន្ទាត់ ហើយមិនសូវមានរលុបអក្សរដូចផ្ទាំងទី១ទេ។ អក្សរចារឹកនេះ រៀបរាប់អំពីពូជពង្សមន្ត្រីម្នាក់ដែលធ្លាប់បានបម្រើរាជការតាំងពីរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នរហូតដល់រាជ្យព្រះបាទជ័យវីរវរ្ម័ន ពោល គឺរៀបរាប់អំពីរឿងជម្លោះជាច្រើនករណី ជាពិសេសគឺជម្លោះដីធ្លីរបស់បូជនីយដ្ឋានសាសនា។ ដើម្បីដោះស្រាយជម្លោះទាំងនេះ ព្រះមហាក្សត្រអង្គនីមួយៗ បានចេញព្រះរាជបញ្ជាប្រើមន្ត្រីមានតួនាទីប្រធានតុលាការចុះទៅកាត់ក្តីផ្ទាល់។ ចំណុចគួរកត់សម្គាល់នោះគឺ ព្រះរាជាទ្រង់បង្គាប់ឲ្យប្រើទណ្ឌកម្មដល់អ្នកដែលចាញ់ក្តី ដូចជា វះមាត់ ទះកំផ្លៀង កាត់ដៃ កាត់ជើង បោះដែកក្តៅលើខ្លួន ។ល។ សិលាចារឹកនេះទំនងចារឹកឡើងនៅក្នុងរជ្ជកាលរបស់ព្រះបាទជ័យវីរវរ្ម័ន ដើមស.វ.ទី១១ (គ.ស. ១០០១-១០០៦ ឬ១០១០) ប៉ុន្តែបានរំឭកព្រឹត្តិការណ៍ចាស់ៗកន្លងមក។ ទិន្នន័យ អក្សរចារឹកនេះក៏បាននាំឲ្យយើងដឹងអំពីអាទិទេពដែលគេបានកសាងមាន *ព្រះកម្រតេងអញលោកេស្វរ* និង*ព្រះកម្រតេងអញតថាគត*[៩]។ ប៉ុន្តែ យើងមិនដឹងថា តើអាទិទេពដែលរៀបរាប់នេះដាក់នៅប្រាសាទនេះមែនឬមិនមែននោះទេ? ប្រសិនបើតម្កល់នៅប្រាសាទនេះមែន មានន័យថា ប្រាសាទអំបែងធំ គឺ កសាងឡើងដើម្បីឧទ្ទិសដល់ព្រះពុទ្ធសាសនាមហាយាន និកាយវជ្រយាន។

---

[៧] Lajonquière 1902: 210; Aymonier 1900: 352; Parmentier 1913:20.

[៨] De Coral Résumsat 1940: 59-60; Boisselier 1966: 165-166.

[៩] កំ វណ្ណារ៉ា ២០១៨: ១០៩។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

# អត្ថបទ៖ ប្រាសាទអំបែងធំ

ជារួមបើយើងពិនិត្យទៅលើស្ថាបត្យកម្មប្រាសាទ និងសិលាចារឹក គឺមិនស៊ីសង្វាក់គ្នានោះទេ ពោល គឺមានន័យថា ប្រាសាទអំបែងធំ កសាងឡើងនៅស.វ.ទី១០ នាចុងរចនាបថប្រែរូប ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៧) ប៉ុន្តែសិលាចារឹកវិញជាគោលចារឹកដែលគេយកទៅតម្កល់នៅសម័យក្រោយ គឺដើមស.វ.ទី១១ ក្នុងរជ្ជកាលព្រះបាទជ័យវីរវរ្ម័ន (គ.ស.១០០១-១០០៦ ឬ១០១០)។ ករណីនេះ គឺមានលក្ខណៈដូចនៅគុកលិចឬប្រាសាទត្នោតជុំខាងលិចស្រុកបារាយណ៍ដូច្នោះដែរ ពោល គឺប្រាសាទសាងនៅរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន និងសិលាចារឹកគេយកទៅតម្កល់នៅរជ្ជកាលព្រះបាទជ័យវីរវរ្ម័នដូចគ្នា។ ប៉ុន្តែ ខុសត្រង់ថានៅគុកលិចឬប្រាសាទត្នោតជុំខាងលិច ពុំមែនរៀបរាប់អំពីជម្លោះ ឬការកាត់ក្តីអ្វីឡើយ គេរៀបរាប់អំពីការបោះបង្គោលព័ទ្ធយកដីព្រៃរំដេង ដែលជាដីទំនេរសម្រាប់សាងសង់ជាសាសនដ្ឋាន។



រូបលេខ១-២៖ ប្រាសាទអំបែងធំ



រូបលេខ៣-៥៖ ប្រាសាទអំបែងធំ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី





រូបលេខ២៦-៧៖ ប្រាសាទអំបែងនំ



រូបលេខ២៨៖ ប្រាសាទត្នោតជុំខាងលិច ឬគុកលិច



រូបលេខ២៩៖ ជើងទម្ររកឃើញនៅប្រាសាទអំបែង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១០៖ បំណែកសសរពេជ្រនៅអំបែងនំ



រូបលេខ១១៖ គោលចារឹកនៅអំបែងនំ

## បញ្ជីឯកសារយោង

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, សាលាបារាំងចុងបូព៌ាប្រទេស**

២០០៨, "បញ្ជីសារពើភណ្ឌស្ថានីយបុរាណនៅខេត្តកំពង់ធំ, ភ្នំពេញ

**ពុទ្ធសាសនបណ្ឌិត្យ**

១៩៦៧, "វចនានុក្រមខ្មែរ, ភ្នំពេញ

**កំ វណ្ណារ៉ា**

២០១៩, "ប្រជុំសិលាចារឹកខេត្តកំពង់ធំ, ភ្នំពេញ

**Aymonier, Etienne**

1900, *"Le Cambodge"*, *Tome I, Le royume actuel*, Paris.

**Boisselier, Jean**

- 1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris

**Coedès, George**

- 1937, A new inscription from Fu-nan, *The journal of the Greater India Society*, IV, 2
- 1954, *Inscription du Cambodge*, Vol VI, Hanoi

**Gilberte, De Coral Rémusat**

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

1940, *L'Art Khmer, Les grandes étapes et son evolution, les éditions d'art et d'histoire*, Paris
**Lunet De Lajonquière**
1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris
**Parmentier, Henri**
1913, "Complément à l'Inventaire descriptif des monuments du Cambodge", *BEFEO,* Tome 13, Paris
**Saveros Pou**
1992, *Dictionnaire Vieux Khmer-Français-Englais*, Paris

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION